**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ..០១០......សហវ.-.៣ខ

រាជធានីភ្នំពេញ. ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០០៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

យោងតាមមាត្រា៣០ថ្មី ក្នុងមាត្រា៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ និងប្រកាសលេខ សហវ.ពដ.ប្រក. ចុះថ្ងៃទី ខែ ឆ្នាំ២០០៧ ស្តីពីការកែប្រែប្រកាសស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជំរាបកម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់នៅតាមខេត្ត-ក្រុង និងរាជធានីភ្នំពេញឱ្យបានជ្រាបថា:

ដីធ្លីមិនបានប្រើប្រាស់ស្ថិតនៅក្នុងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។ ដូចមានចែងក្នុងមាត្រា៣០ថ្មី ក្នុងមាត្រា៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ក្នុងការគិតពន្ធ មិនត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីមូលដ្ឋានកំណត់ពន្ធចំនួន ១.២០០ ម៉ែត្រក្រឡាសំរាប់ដីមួយកន្លែងទៀតទេ ។

- ពន្ធនេះត្រូវបង់តាមអត្រា ២ ភាគរយ លើមូលដ្ឋានកំណត់ពន្ធ ដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ផ្អែកលើតំលៃទីផ្សារ តាមទីក្រុង និងតាមតំបន់នីមួយៗ ដែលវាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡាសំរាប់ឆ្នាំនីមួយៗ ។
- កម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់នីមួយៗ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធចំនួនពីរច្បាប់ និងគណនាប្រាក់ពន្ធដោយខ្លួនឯង ទៅតាមគំរូលិខិតប្រកាសដែលនាយកដ្ឋានពន្ធដារផ្តល់ជូន ហើយត្រូវបង់ពន្ធឱ្យបានចប់សព្វគ្រប់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំសារពើពន្ធនីមួយៗ ជូនទៅសាខាពន្ធដារខេត្ត-ក្រុង ដែលដីធ្លីនោះស្ថិតនៅ ។ ក្នុងករណីដែលកម្មសិទ្ធិករមិនបានដាក់លិខិតប្រកាសបង់ពន្ធ ឬមិនបានបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវរងការដាក់ឱ្យអនុវត្តតាមមាត្រា១១៦ និង១១៧នៃច្បាប់ស្តីពីសារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ពើពន្ធ ។ ទន្ទឹមនឹងនេះផ្អែកតាមមាត្រា ១៣១ និងមាត្រា១៣២នៃច្បាប់ដដែលខាងលើ កម្មសិទ្ធិករត្រូវទទួលរងពិន័យបង់ប្រាក់ពន្ធបន្ថែមស្មើនឹង១០ភាគរយ ២៥ភាគរយ និង៤០ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសំរាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួន ប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមនិងជឿជាក់ថា កម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់ទាំងអស់ប្រាកដជាយកចិត្តទុកដាក់បំពេញកាតព្វកិច្ចសារពើពន្ធ បានល្អប្រសើរជាពុំខាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង " ដើម្បីជូនជ្រាប "
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ " ដើម្បីមុខការ "
- គ្រប់អង្គភាពពន្ធដារ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ ។